ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 19 / 06 / 2019
ម៉ោង (Time/Heure): 13:10
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៦០)

## របាយការណ៍នៃសំណុំរឿង និង បណ្តឹងឧទ្ធរណ៍

I- សេចក្តីផ្តើម

II- ការកំណត់អត្តសញ្ញាណជនត្រូវចោទ

III- សាវតារសំណុំរឿង

IV- ដីកាដំណោះស្រាយក្រោមបណ្តឹងឧទ្ធរណ៍

V- ទិដ្ឋភាពទូទៅនៃកិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍ និងបញ្ហានានាដែលបានលើកឡើង

VI- សេចក្តីសន្និដ្ឋាន

### I. សេចក្តីផ្តើម

របាយការណ៍នេះត្រូវបានចេញក្នុងនាមអង្គបុរេជំនុំជម្រះទាំងមូល។ របាយការណ៍រៀបរាប់នូវអង្គហេតុ និងប្រវត្តិនីតិវិធីនៃសំណុំរឿង ០០៤/២ ព្រមទាំងព័ត៌មានលម្អិតនៃបណ្តឹងឧទ្ធរណ៍ដែលបានដាក់នាពេលបច្ចុប្បន្ននៅចំពោះមុខអង្គជំនុំជម្រះនេះ។

### II. ការកំណត់អត្តសញ្ញាណជនត្រូវចោទ

ជនត្រូវចោទ អោ អាន ដែលមានឈ្មោះកំណើត អោម យឿង ឬ អោ យឿង ជាជនជាតិខ្មែរ កើតនៅឆ្នាំ១៩៣៣ នៅភូមិតាំងស្វាយ ឃុំពាម ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ បច្ចុប្បន្ន គាត់មានទីលំនៅ

នៅខេត្តបាត់ដំបង [1] ។ អោ អាន បានដាក់ជូនអង្គបុរេជំនុំជម្រះនូវរបាយការណ៍ស្តីពីស្ថានភាពសុខភាព ដែលបញ្ជាក់ថាលោក អោ អាន មិនអាចធ្វើដំណើរឆ្ងាយ ដើម្បីចូលរួមសវនាការ។

អោ អាន ត្រូវបានតំណាងដោយសហមេធាវីការពារក្តីលោក មុំ លុជ្ស លោក Richard ROGERS និង លោក Göran SLUITER។

## III. សាវតារសំណុំរឿង

នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ករណីខ្វែងយោបល់គ្នានៅចំពោះមុខអង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ៧១(២) នៃវិធានផ្ទៃក្នុង ដោយរាយការណ៍ថា សហព្រះរាជអាជ្ញាជាតិមិនយល់ស្របទៅនឹងការចោទប្រកាន់បទឧក្រិដ្ឋថ្មីៗ ដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម [2] ។ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណាស្តីពីករណីខ្វែងយោបល់គ្នា [3] ។ ករណីខ្វែងយោបល់គ្នាសម្ងាត់មួយចំនួនក៏ត្រូវបានចុះបញ្ជីផងដែរ រវាងសហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿងនេះ តែពុំមានករណីខ្វែងយោបល់គ្នាណាមួយក្នុងចំណោមករណីខ្វែងយោបល់ទាំងនេះត្រូវបានដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះទេ។

នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ បន្ទាប់មានបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមចំនួនប្រាំមួយ ដោយស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតបើកកិច្ចស៊ើបសួរប្រឆាំងនឹង អោ អាន ក្នុងចំណោមចំណុចនានាផ្សេងទៀត ទាក់ទងនឹងការចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងការរំលោភទៅលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ដែល

---

1 [redacted]

2 ករណីខ្វែងយោបល់គ្នា ០០១/១៨-១១-២០០៨/អ.វ.ត.ក/អ.ប.ជ សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីអង្គហេតុ និងសំអាងហេតុចំពោះករណីខ្វែងយោបល់គ្នា អនុលោមតាមវិធាន ៧១(២) ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1។

3 ករណីខ្វែងយោបល់គ្នា ០០១/១៨-១១-២០០៨/អ.វ.ត.ក/អ.ប.ជ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារ D1/1.3។

បានប្រព្រឹត្តនៅក្នុងតំបន់ ៤១ តំបន់ ៤២ និង តំបន់ ៤៣ នៃភូមិភាគកណ្តាល ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ[4]។

នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥[5] និង ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦[6] សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់ អោ អាន ពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាច្រើន និងឧក្រិដ្ឋកម្មជាតិនៃអំពើមនុស្សឃាតគិតទុកជាមុន ដែលបានប្រព្រឹត្តប្រហែលពីចុងឆ្នាំ១៩៧៦ យ៉ាងហោចណាស់រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ក្នុងឋានៈគាត់ជាអនុលេខាភូមិភាគកណ្តាល សមាជិកគណៈកម្មាធិការភូមិភាគកណ្តាល និងលេខាតំបន់ ៤១ នៅក្នុងភូមិភាគកណ្តាល។ ការចោទប្រកាន់នានាដែលបានអះអាងថា ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តនៅទីកន្លែងជាច្រើននៅភូមិភាគកណ្តាល រួមមានការដ្ឋានការងារ មន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្ស នៅក្នុងតំបន់ ៤១ តំបន់ ៤២ និង តំបន់ ៤៣[7]។

---

[4] សំណុំរឿង ០០៤/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1។ សំណុំរឿង ០០៤/០៧-០៩-២០០៩/អ.វ.ត.ក/ក.ស.ច.ស (“សំណុំរឿង ០០៤”) ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D27។ សំណុំរឿង ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ ឯកសារ D65។ សំណុំរឿង ០០៤ ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវត្តតាមាក់ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១១ ឯកសារ D254/1។ សំណុំរឿង ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ អំពើហិង្សាផ្លូវភេទ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ឯកសារ D191។ សំណុំរឿង ០០៤ ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ឯកសារ D237 ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ D237/1។ សំណុំរឿង ០០៤ ចម្លើយតបទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរទៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងតំបន់ ១ និង តំបន់ ៤ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ និងបានដាក់នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៦ ឯកសារ D272/1។

[5] សំណុំរឿង ០០៤ កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ អោ អាន ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ ឯកសារ D242 (“កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ អោ អាន (ឯកសារ D242)”)។

[6] សំណុំរឿង ០០៤ កំណត់ហេតុនៃការបង្ហាញខ្លួនម្តងទៀតរបស់ អោ អាន ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ ឯកសារ D303 (“កំណត់ហេតុនៃការបង្ហាញខ្លួនម្តងទៀតរបស់ អោ អាន (ឯកសារ D303)”)។

[7] ទីតាំងជាក់លាក់ដែលបានលើកឡើងនៅក្នុងឯកសារចោទប្រកាន់រួមមាន៖ ទាក់ទិននឹងអំពើប្រល័យពូជសាសន៍ គឺភូមិភាគកណ្តាល ទាក់ទិននឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្ស និងឧក្រិដ្ឋកម្មជាតិ គឺទំនប់អន្លង់ជ្រៃ ទីកន្លែងសម្លាប់មនុស្សគោកព្រីង មន្ទីរសន្តិសុខមិត្តសុប មន្ទីសន្តិសុខទួលបេង និងវត្តអង្គញជី មន្ទីរសន្តិសុខវត្តអូរត្រកួន មន្ទីរសន្តិសុខវត្តបាធាយ ទីតាំងសម្លាប់មនុស្សវត្តភ្នំប្រុស មន្ទីរសន្តិសុខវត្តតាមាក់ មន្ទីរសន្តិសុខចម្ការស្វាយចន្ទី មន្ទីរសន្តិសុខវត្តបារាយជាន់ដែក មន្ទីរសន្តិសុខវត្តស្រង៉ែ និង ស្រុកកំពង់

ទម្រង់នៃការទទួលខុសត្រូវដែលតាមរយៈនោះ អោ អាន ត្រូវបានចោទប្រកាន់មានភាពខុសប្លែកគ្នាអាស្រ័យទៅលើឧក្រិដ្ឋកម្ម និងទីកន្លែង និងរួមមាន៖ ការប្រព្រឹត្តិតាមរយៈសហឧក្រិដ្ឋកម្មរួម ការចូលរួមប្រព្រឹត្តិជាសហចារី ការរៀបចំផែនការ ការបញ្ជា ឬការញុះញង់ និង ការទទួលខុសត្រូវរបស់ថ្នាក់លើ[8]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចមិនដាក់ អោ អាន ក្នុងការឃុំខ្លួនបណ្តោះអាសន្នក្នុងអំឡុងពេលស៊ើបអង្កេតទេ តែបានជូនដំណឹងដល់គាត់ថា គាត់ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ អ.វ.ត.ក[9]។

នៅពេលបង្ហាញខ្លួនបឋមរបស់គាត់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតអន្តរជាតិ អោ អាន បានសំដែងការសោកស្តាយចំពោះការឈឺចាប់របស់ជនរងគ្រោះ ក្នុងរបបខ្មែរក្រហម តែគាត់បានបដិសេធថាគាត់ពុំមានការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការឈឺចាប់នោះទេ[10]។

នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចកាត់បន្ថយវិសាលភាពនៃការស៊ើបអង្កេត ដោយដកចេញនូវការចោទប្រកាន់ទាំងអស់ពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនៅក្នុងតំបន់ ៤២ និង តំបន់ ៤៣ និង ការចាប់ខ្លួន និងការសម្លាប់ជនជាតិចាមនៅភូមិភាគបូព៌ា[11]។ ហេតុនេះ ការចោទប្រកាន់ទាំងនេះលែងបង្កើតជាមូលដ្ឋានសម្រាប់បទចោទប្រកាន់ អោ អាន ទៀតហើយ[12]។ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ផងដែរ សហចៅក្រមស៊ើបអង្កេតទាំងពីររូបបានចេញដីកាសម្រេចបំបែកការស៊ើបអង្កេតប្រឆាំង អោ អាន ចេញពីសំណុំរឿង ០០៤ និងបង្កើតជាសំណុំរឿង ០០៤/២[13]។

---

សៀម និងស្រុកព្រៃឈរ។ *សូមមើល* កំណត់ហេតុនៃការបង្ហាញខ្លួនម្តងទៀតរបស់ អោ អាន (ឯកសារ D303)។

[8] កំណត់ហេតុនៃការបង្ហាញខ្លួនម្តងទៀតរបស់ អោ អាន (ឯកសារ D303)

[9] កំណត់ហេតុនៃការបង្ហាញខ្លួនម្តងទៀតរបស់ អោ អាន (ឯកសារ D303) ទំព័រ ១១-១២។ កំណត់ហេតុនៃការបង្ហាញខ្លួនម្តងទៀតរបស់ អោ អាន (ឯកសារ D303) ទំព័រ ១៥។

[10] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ អោ អាន (ឯកសារ D242) ទំព័រ ៨-៩។

[11] សំណុំរឿង ០០៤ ដីកាសម្រេចបន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ D337 កថាខណ្ឌ ៤, ១៣។ *សូមមើលផងដែរ* សំណុំរឿង ០០៤/២ សេចក្តីជូនដំណឹងយោងតាមវិធាន ៦៦*ស្ទួន*(២) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ D307/4។ មានការដកចេញផងដែរនូវការចោទប្រកាន់ពីការធ្វើទារុណកម្មនៅ មន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្ស ទួលបេង និងវត្តអង្គញជី និងការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើទុក្ខបុកម្នេញនៅមន្ទីរសន្តិសុខវត្តភ្នំប្រុស។

[12] វិធាន ៦៦*ស្ទួន*(៥) នៃវិធានផ្ទៃក្នុង។

[13] សំណុំរឿង ០០៤ ដីកាសម្រេចបំបែកសំណុំរឿង អោ អាន ចេញពីសំណុំរឿង ០០៤ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ D334/1។

នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្ដីជូនដំណឹងស្ដាពរមួយស្ដីពីការបញ្ចប់កិច្ចស៊ើបសួរ[14] ហើយនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានបញ្ជូនសំណុំរឿងទៅសហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ដោយស្នើឱ្យសហព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានស្ដាពរក្នុងរយៈពេលបីខែ [15] ។ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ សហព្រះរាជអាជ្ញាជាតិបានដាក់ដីកាសន្និដ្ឋានស្ដាពរមួយដោយស្នើសុំឱ្យលើកលែងការចោទប្រកាន់ទាំងអស់[16] ហើយនៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានស្ដាពរមួយដោយស្នើសុំឱ្យចោទប្រកាន់ អោ អាន និងបញ្ជូនគាត់ទៅជំនុំជម្រះ[17]។ អោ អាន បានដាក់ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ដាពររបស់សហព្រះរាជអាជ្ញានៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ដោយជំទាស់ថា ការចោទប្រកាន់នៅក្នុងសំណុំរឿងនេះគួរត្រូវបានលើកលែង[18]។

## IV. ដីកាដំណោះស្រាយក្រោមបណ្ដឹងឧទ្ធរណ៍

### ក. សេចក្ដីផ្ដើម

អនុលោមតាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង "សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយ [ដោយមានសំអាងហេតុ] ថាត្រូវចោទប្រកាន់ និង បញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់" [19] ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ "ត្រូវបញ្ជាក់អំពីអត្តសញ្ញាណរបស់ជនជាប់ចោទ ការបង្ហាញអំពីអង្គហេតុ និងការកំណត់ប្រភេទបទល្មើសដោយសហចៅក្រមស៊ើបអង្កេតក្នុងនោះមានទាំងបទប្បញ្ញត្តិនៃបទឧក្រិដ្ឋដែលពាក់ព័ន្ធ និងប្រភេទនៃទទួលខុសត្រូវព្រហ្ម

---

[14] សំណុំរឿង ០០៤/២ សេចក្ដីជូនដំណឹងលើកទី២ អំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ ឯកសារ D334/2។

[15] សំណុំរឿង ០០៤/២ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D351។

[16] សំណុំរឿង ០០៤/២ ដីកាសន្និដ្ឋានស្ដាពរ ទាក់ទងករណី អោ អាន អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/4។

[17] សំណុំរឿង ០០៤/២ ដីសន្និដ្ឋានស្ដាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/5។

[18] សំណុំរឿង ០០៤/២ ចម្លើយតបរបស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានស្ដាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ឯកសារ D351/6។

[19] វិធាន ៦៧(១) នៃវិធានផ្ទៃក្នុង។

ទណ្ឌ"[20]។ "សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាលើកលែងចោទប្រកាន់" ក្នុងករណីដូចខាងក្រោម៖ (ក) អំពើដែលចោទប្រកាន់មិនរាប់ចូលជាបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក (ខ) ជនប្រព្រឹត្តបទឧក្រិដ្ឋនោះមិនទាន់កំណត់អត្តសញ្ញាណនៅឡើយ ឬ (គ) ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនត្រូវចោទ[21]។

នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ភាគីថា សហចៅក្រមស៊ើបអង្កេតពិចារណាចេញដីកាដំណោះស្រាយដាច់ពីគ្នា និងផ្ទុយគ្នា ដែលត្រូវបានអនុញ្ញាតជាទូទៅក្រោមច្បាប់ជាធរមាន[22]។ សហចៅក្រមស៊ើបអង្កេតបានចុះបញ្ជីនូវករណីខ្វែងយោបល់គ្នាមួយពាក់ព័ន្ធនឹងការចេញដីកាដំណោះស្រាយផ្ទុយគ្នានៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨ តែករណីខ្វែងយោបល់គ្នានេះមិនត្រូវបានដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះទេ។

នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ដោយបញ្ជូន អោ អាន ទៅជំនុំជម្រះ[23] ចំណែកសហចៅក្រមស៊ើបអង្កេតជាតិបានចេញដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) ដោយលើកលែងបទចោទទាំងអស់ប្រឆាំងរូបគាត់[24]។ ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នាបែបនេះជាករណីតែមួយគត់ដែលពុំធ្លាប់មានពីមុនមក។

នាពេលនេះ យើងនឹងលើកឡើងនូវទិដ្ឋភាពទូទៅនៃដីកាដំណោះស្រាយនីមួយៗដែលបានចេញនៅក្នុងសំណុំរឿងនេះ។

### ខ. ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ)

---

[20] វិធាន ៦៧(២) នៃវិធានផ្ទៃក្នុង។

[21] វិធាន ៦៧(៣) នៃវិធានផ្ទៃក្នុង។

[22] សំណុំរឿង ០០៤/២ ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D355/1 កថាខណ្ឌ ១៣-១៦។

[23] សំណុំរឿង ០០៤/២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360 ("ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360)")។

[24] សំណុំរឿង ០០៤/២ ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D359 ("ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D359)")។

នៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសន្និដ្ឋានថា នៅចន្លោះពីចុងឆ្នាំ១៩៧៦ រហូតដល់ដើមឆ្នាំ១៩៧៧ អោ អាន បានធ្វើដំណើរជាមួយកម្មាភិបាលភូមិភាគពាយ័ព្យមួយក្រុមទៅភូមិភាគកណ្តាល ដែលនៅពេលនោះ កែ ពក បានតែងតាំងគាត់ធ្វើជាលេខាតំបន់ ៤១ ជាមុខតំណែងដែលគាត់កាន់រហូតដល់ចប់សម័យកម្ពុជាប្រជាធិបតេយ្យ ហើយដែលធ្វើឱ្យគាត់ក្លាយជាសមាជិកគណៈកម្មាធិការភូមិភាគកណ្តាលដោយស្វ័យប្រវត្តិ[25]។ នៅក្នុងតួនាទីនេះ អោ អាន បានអនុវត្តសិទ្ធិអំណាចផ្នែកយោធា និងស៊ីវិលទាំងស្រុងទៅលើតំបន់ ៤១[26]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសន្និដ្ឋានបន្ថែមថា ភស្តុតាងបានបង្ហាញយ៉ាងពេញលេញថា អោ អាន បានកាន់មុខតំណែងជាអនុលេខាភូមិភាគកណ្តាលពីចុងឆ្នាំ១៩៧៧ រហូតដល់ចប់របបនោះ បំពេញការងារជាលេខាភូមិភាគកណ្តាលស្តីទីនៅពេល កែ ពក អវត្តមាន[27] និង បានដើរតួនាទីសំខាន់នៅក្នុងរដ្ឋបាលថ្នាក់ភូមិភាគ ដោយសិទ្ធិអំណាចរបស់គាត់បានលាតសន្ធឹងទៅលើបញ្ហាយោធា និងសន្តិសុខទៀតផង[28]។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសន្និដ្ឋានថា ប្រហែលពីចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ រហូតដល់យ៉ាងហោចណាស់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ អោ អាន, កែ ពក និងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក) ដទៃទៀត បានចែករំលែកនូវគោលបំណងរួមនៃការអនុវត្តគោលនយោបាយ ប.ក.ក ទាំងបួនចំណុចនៅក្នុងភូមិភាគកណ្តាលនៃរបបកម្ពុជាប្រជាធិបតេយ្យ តាមរយៈការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាច្រើន និងអំពើប្រល័យពូជសាសន៍[29]។ គោលនយោបាយទាំងនោះរួមមាន៖ (១) ការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋាន (២) ការកសាង "សមាសភាពមិនល្អ" និងការសម្លាប់ "ខ្មាំង" (៣) ការកំណត់គោលដៅលើក្រុមជាក់លាក់ រួមទាំងកម្មាភិបាល ប.ក.ក នៅភូមិភាគកណ្តាល អតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ "ប្រជាជន ១៧ មេសា" ប្រជាជនមកពីភូមិភាគបូព៌ា ជនជាតិចាម និងក្រុមគ្រួសារ និង (៤) ការដាក់បទបញ្ជាលើការរៀបអាពាហ៍ពិពាហ៍[30]។

---

25 *សូមមើល* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៤២-២៥០។

26 ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៥៦-២៦៣។

27 *សូមមើល* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៥០-២៥៥។ *សូមមើលផងដែរ* កថាខណ្ឌ ៧០០-៧០៥។

28 ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៥៦-២៦៣។

29 ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ១៩៥, ៨២៤។

30 ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ១៩៥, ៨២៤។

បើតាមសហចៅក្រមស៊ើបអង្កេតអន្តរជាតិ អោ អាន បានដើរតួនាទីសំខាន់ក្នុងការអនុវត្តនូវគោលនយោបាយទាំងនេះ [31] ។ ឧទាហរណ៍ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសន្និដ្ឋានថា គាត់មានតួនាទីស្រួចស្រាល់ក្នុងការសម្របសម្រួល និងអនុវត្តអំពើប្រល័យពូជសាសន៍ទៅលើជនជាតិចាមនៅភូមិភាគកណ្ដាល ជាពិសេសនៅក្នុងតំបន់ ៤១ ទាំងមូល[32]។

ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) លើកឡើងថា "ការគណនាចំនួនតាមបែបអភិរក្សនិយមខ្លាំង" ថា "ជនជាតិចាមយ៉ាងតិចបំផុតចំនួន ១៧.១១៥ នាក់ ត្រូវបានសម្លាប់នៅភូមិភាគកណ្ដាល នៅក្នុងអំឡុងពេលដែល អោ អាន កាន់តំណែង" [33] ។ ដីកានេះក៏លើកឡើងផងដែរថា "មនុស្សចំនួន ១២.៩៤៤ នាក់ ជាចំនួនប៉ាន់ស្មានយ៉ាងតិចបំផុត (រាប់បញ្ចូលទាំងជនជាតិចាមយ៉ាងហោចណាស់ចំនួន ១.៧៤៣ នាក់) ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្សដែល អោ អាន ទទួលខុសត្រូវ" ចំណែក "ប្រជាជនរាប់ពាន់នាក់ត្រូវបានបង្ខំឱ្យធ្វើការក្នុងស្ថានភាពលំបាកខ្លាំង និងគំរាមសម្លាប់" នៅតាមការដ្ឋានដែល អោ អាន ទទួលខុសត្រូវ[34]។

ទាក់ទិននឹងមុខតំណែង និងការប្រព្រឹត្តរបស់ អោ អាន ព្រមទាំងអត្តចរិត និងវិសាលភាពនៃឧក្រិដ្ឋកម្មរបស់គាត់វិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសន្និដ្ឋានថា គាត់ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតម្នាក់ក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ ហេតុនេះគាត់ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[35]។

ក្រោយពេលពិនិត្យភស្តុតាង [36] និងបានសន្និដ្ឋានថា មានការបង្ហាញនូវធាតុផ្សំគតិយុត្តិនៃឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវ[37] រួចមក សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចចោទប្រកាន់ អោ អាន និងបញ្ជូនគាត់ទៅជំនុំជម្រះចំពោះ៖

---

[31] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៦៤-៣១៩, ៧១២។

[32] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ១៩៥, ៨២៤។

[33] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៧០៩។

[34] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៧១១។

[35] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៦៩៧-៧១២។

[36] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) ផ្នែក ៦។

[37] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) ផ្នែក ៨-៩។

- អំពើប្រល័យពូជសាសន៍ទៅលើជនជាតិចាមនៅខេត្តកំពង់ចាម តាមរយៈការសម្លាប់សមាជិកទាំងឡាយនៃក្រុម និងការបង្កនូវព្យសនកម្មផ្លូវកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរទៅលើបណ្ដាសមាជិកទាំងឡាយនៃក្រុម តាមរយៈការប្រព្រឹត្តិដោយសហឧក្រិដ្ឋកម្មរួម ឬតាមរយៈការធ្វើផែនការ ការបញ្ជា ឬការញុះញង់ ឬតាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើ។

- ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទារុណកម្ម ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើឱ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ និងសាសនា និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ដូចជា *ក្នុងចំណោមចំណុចផ្សេងទៀត* អាពាហ៍ពិពាហ៍ដោយបង្ខំ) ដែលបានប្រព្រឹត្តនៅទីតាំងឧក្រិដ្ឋកម្មចំនួនប្រាំបួន ក្នុងតំបន់ ៤១ នៃភូមិភាគកណ្ដាល រួមមាន ការដ្ឋានពលកម្មដោយបង្ខំទំនប់អន្លង់ជ្រៃ ទីតាំងសម្លាប់មនុស្សគោកព្រីង មន្ទីរសន្តិសុខមិត្តសុប មន្ទីរសន្តិសុខទួលបេង និងមន្ទីរសន្តិសុខវត្តអង្គញ្ជីម មន្ទីរសន្តិសុខវត្តអូរត្រកួន មន្ទីរសន្តិសុខវត្តបាធាយ ទីតាំងសម្លាប់មនុស្សវត្តភ្នំប្រុស មន្ទីរសន្តិសុខវត្តតាមាក់ និង ស្រុកកំពង់សៀម និងស្រុកព្រៃឈរ តាមរយៈការប្រព្រឹត្តិក្នុងនាមជាចារីផ្ទាល់ និង/ឬ តាមរយៈសហឧក្រិដ្ឋកម្មរួម ឬតាមរយៈការធ្វើផែនការ ការបញ្ជា ឬការញុះញង់ ឬតាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើ។

- និង ពាក់ព័ន្ធនឹងអំពើមនុស្សឃាតដោយគិតទុកជាមុន ជាការរំលោភបំពានទៅលើមាត្រា ៥០១ និង មាត្រា ៥០៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ដែលបានប្រព្រឹត្តនៅទីតាំងឧក្រិដ្ឋកម្មចំនួនប្រាំបីក្នុងតំបន់ ៤១ នៃភូមិភាគកណ្ដាល រួមមាន ការដ្ឋានពលកម្មដោយបង្ខំទំនប់អន្លង់ជ្រៃ ទីតាំងសម្លាប់មនុស្សគោកព្រីង មន្ទីរសន្តិសុខមិត្តសុប មន្ទីរសន្តិសុខទួលបេង និងមន្ទីរសន្តិសុខវត្តអង្គញ្ជីម មន្ទីរសន្តិសុខវត្តអូរត្រកួន មន្ទីរសន្តិសុខវត្តបាធាយ ទីតាំងសម្លាប់មនុស្សវត្តភ្នំប្រុស និង មន្ទីរសន្តិសុខវត្តតាមាក់ តាមរយៈការចូលរួមប្រព្រឹត្តិជាសហចារី ឬ ការធ្វើផែនការ ឬការបញ្ជា[38]។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានលើកលែងចោទប្រកាន់ចំពោះបទចោទមួយចំនួនស្ដីពីការធ្វើទុក្ខបុកម្នេញ ការសម្លាប់រង្គាល និងអំពើប្រល័យពូជសាសន៍ ដោយសារពុំមានភស្តុតាងគ្រប់គ្រាន់[39]

---

[38] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) ទំព័រ ៦៨២-៦៨៩។

[39] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) ទំព័រ ៦៨០-៦៨១។

និងបានសម្រេចថា ការឃុំខ្លួនមុនការជំនុំជម្រះមិនមែនជាការចាំបាច់ឡើយ អនុលោមតាមវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង[40]។

**គ. ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់)**

នៅក្នុងដីកាដំណោះស្រាយ (លើកលែងចោទប្រកាន់) សហចៅក្រមស៊ើបអង្កេតជាតិ បានសម្រេចមិនកំណត់បទល្មើស ឬទម្រង់នៃការទទួលខុសត្រូវ[41] ប៉ុន្តែបានពិចារណាលើអង្គហេតុពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មតាមការចោទប្រកាន់នៅក្នុងភូមិភាគកណ្តាលក្នុងការវាយតម្លៃរបស់ខ្លួនថាតើ អោ អាន ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អវតក ដែរឬយ៉ាងណា[42]។ ចំពោះចំណុចនេះ សហចៅក្រមស៊ើបអង្កេតជាតិបានរកឃើញភស្តុតាងនៃអំពើ ជាអាទិ៍ ការធ្វើមនុស្សឃាត ការចាប់ខ្លួន ការឃុំខ្លួន ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការបាត់ខ្លួន និង ការវាយដំ ដែលប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខ កន្លែងសម្លាប់មនុស្ស និង ការដ្ឋានធ្វើពលកម្មដោយបង្ខំនៅក្នុងតំបន់៤១ តំបន់៤២ និង តំបន់៤៣[43] ព្រមទាំង ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅស្រុកកំពង់សៀម និង ស្រុកព្រៃឈរនៃភូមិភាគ៤១ និង អំពើប្រល័យពូជសាសន៍ជនជាតិចាមនៅខេត្តកំពង់ចាម[44]។

សហចៅក្រមស៊ើបអង្កេតជាតិថែមទាំងបានទទួលយកថា អោ អាន បានបម្រើការជាលេខាតំបន់៤១ អស់រយៈពេលជាងមួយឆ្នាំ និង ជាអនុលេខាភូមិភាគកណ្តាលមួយរយៈពេលខ្លី ទោះបីជាពុំមានឯកសារផ្លូវការនៃរបបកម្ពុជាប្រជាធិបតេយ្យដែលបញ្ជាក់អំពីការតែងតាំង អោ អាន ក៏ដោយ[45]។ គាត់ក៏បានពិភាក្សាអំពីភស្តុតាង អោ អាន ចុះទៅមើល និង ទទួលព័ត៌មានអំពីទីតាំងឧក្រិដ្ឋកម្មនានា ផ្តល់ការណែនាំលើការអនុវត្តគោលនយោបាយ ប.ក.ក បញ្ជាសម្លាប់នៅមន្ទីរសន្តិសុខ និង កន្លែងសម្លាប់មនុស្ស និង ចេញ បញ្ជាចាប់ខ្លួន និង

---

[40] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៨៥៣។

[41] ដីកាលើកលែងចោទប្រកាន់ (ឯកសារ D359) កថាខណ្ឌ ២។

[42] ដីកាលើកលែងចោទប្រកាន់ (ឯកសារ D359) កថាខណ្ឌ ២៨៥-៤១៨។

[43] ជាពិសេស វត្តភ្នំប្រុស វត្តអូរត្រកួន វត្តបាធាយ មិត្តសុប(គរ) គោកព្រីង ទំនប់អន្លង់ជ្រៃ វត្តតាមិះ ទួលតាផ្លុង វត្តកណ្តាល ចម្ការស្វាយចន្ទី វត្តបារាយជាន់ដែក វត្តស្រង៉ែ វត្តអង្គញដី និងទួលបេង។

[44] ដីកាលើកលែងចោទប្រកាន់ (ឯកសារ D359) កថាខណ្ឌ ២៨៩-៤១៨។

[45] ដីកាលើកលែងចោទប្រកាន់ (ឯកសារ D359) កថាខណ្ឌ ១៩៩-២០០, ២៤២-២៤៥, ៤៩៥, ៥៤៥។

សម្លាប់ជនជាតិចាមនៅបណ្តាស្រុកនានាក្នុងខេត្តកំពង់ចាម ទោះបីជាសហចៅក្រមស៊ើប អង្កេតជាតិ បានកត់សម្គាល់ថាសាក្សីមួយចំនួននិយាយថាបញ្ជាទំនងជាចេញពីថ្នាក់លើក៏ដោយ[46]។

ទោះជាយ៉ាងណាក៏ដោយ សហចៅក្រមស៊ើបអង្កេតជាតិរកឃើញថា អោ អាន មិនស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឡើយ ដោយ អោ អាន មិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬជាជនដែលទទួលខុសត្រូវខ្ពស់បំផុតនោះឡើយ ដោយផ្អែកលើតួនាទី និង ការចូលរួមរបស់ អោ អាន នៅក្នុងអំពើឧក្រិដ្ឋ និង ប.ក.ក លក្ខណៈទូទៅនៃរបបកម្ពុជាប្រជាធិបតេយ្យ និង គោលនយោបាយរបស់របបនោះ និងចេតនាពិតប្រាកដរបស់អ្នកចរចាកិច្ចព្រមព្រៀងបង្កើត អ.វ.ត.ក[47]។

ជាពិសេស សហចៅក្រមស៊ើបអង្កេតជាតិ បានរកឃើញថា អោ អាន មិនមែនជាសមាជិក ឬ សមាជិកត្រៀមនៃគណៈកម្មាធិការមជ្ឈិម ប.ក.ក ហេតុដូច្នេះ មិនមែនជា "មេដឹកនាំជាន់ខ្ពស់" ឡើយ[48]។ សហចៅក្រមស៊ើបអង្កេតជាតិថែមទាំងរកឃើញថា អោ អាន គ្រប់គ្រងកិច្ចការរដ្ឋបាល និង ចាត់ចែងទូទៅនៅក្នុងតំបន់៤១ ប៉ុន្តែពុំមានភស្តុតាងបញ្ជាក់ថា អោ អាន ទទួលខុសត្រូវកិច្ចការយោធា សន្តិសុខ ឬសេដ្ឋកិច្ចភូមិភាគ ឬថា បានចូលរួមក្នុងការបង្កើតគោលនយោបាយ ប.ក.ក ឡើយ [49] ។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតជាតិយល់ឃើញថា ភស្តុតាងបង្ហាញថា អោ អាន បានប្រព្រឹត្តតាមបញ្ជា និងការណែនាំ របស់ កែ ពក ដែលជាលេខាភូមិភាគកណ្តាល[50]។

សហចៅក្រមស៊ើបអង្កេតជាតិ ចោទសួរបន្ថែមទៀតទៅលើភាពគួរឲ្យជឿទុកចិត្តបាននៃភស្តុតាងដែលបង្ហាញអំពីការចូលរួមរបស់ អោ អាន នៅក្នុងបទឧក្រិដ្ឋដែលបានចោទ ក្នុងនោះរួមមានការចាប់ខ្លួន និង ការសម្លាប់ ការប្រព្រឹត្តិលើជនជាតិចាមនៅក្នុងខេត្តកំពង់ចាម និង អាពាហ៍ពិពាហ៍ដោយបង្ខំក្នុងតំបន់៤១ [51] និង ពិចារណាឃើញថា ការចូលរួមណាមួយបែបនេះគឺស្របទៅនឹងគោលនយោបាយជាប្រព័ន្ធខ្សែ បណ្តោយរបស់ ប.ក.ក

---

[46] ដីកាលើកលែងចោទប្រកាន់ (ឯកសារ D359) កថាខណ្ឌ ២៨៩-៤១៨ ជាពិសេសកថាខណ្ឌ ២៩២, ២៩៤-២៩៥, ៣០៨-៣០៩, ៣២៨-៣៣០, ៣៣៨, ៣៤៨, ៣៩៨, ៤០១-៤០២, ៤០៤, ៤១០-៤១១, ៤១៣, ៤១៥-៤១៨។

[47] ដីកាលើកលែងចោទប្រកាន់ (ឯកសារ D359) កថាខណ្ឌ ១៧, ៤៩២។

[48] ដីកាលើកលែងចោទប្រកាន់ (ឯកសារ D359) កថាខណ្ឌ ៤៧២, ៥០៧, ៥២៣។

[49] ដីកាលើកលែងចោទប្រកាន់ ឯកសារ (D359) កថាខណ្ឌ ៤៩៦, ៥៥៣។

[50] ដីកាលើកលែងចោទប្រកាន់ (ឯកសារ D359) កថាខណ្ឌ ៤៩៦, ៥១០-៥១១, ៥១៨, ៥៥២។

[51] ដីកាលើកលែងចោទប្រកាន់ (ឯកសារ D359) កថាខណ្ឌ ៤៩៧-៥០៦។

ដែលកម្មាភិបាលត្រូវតែអនុវត្តដាច់ខាត បើមិនដូច្នោះទេនឹងត្រូវបោសសម្អាត [52] ។ អោ អាន ខ្លួនឯងក៏បានបញ្ជាក់ថា ខ្លួនត្រូវតែអនុវត្តតាមបញ្ជាដាច់ខាត ហើយភ័យខ្លាចបាត់បង់ជីវិតប្រសិនបើខ្លួនមិនអនុវត្តតាម[53]។

ជាចុងក្រោយ សហចៅក្រមស៊ើបអង្កេតជាតិបានរកឃើញថា មុន និង កំឡុងពេលចរចាបង្កើត អ.វ.ត.ក ភាគីកម្ពុជាមានបំណងចង់បានយុត្តាធិការបុគ្គលមានលក្ខណៈចង្អៀត និង ជ្រើសរើស ដែលប្រភេទ "ជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត" គឺសំដៅត្រឹមតែ កាំង ហ្កេចអ៊ាវ ហៅ ឌុច ប៉ុណ្ណោះ[54]។ យោងតាមសហចៅក្រមស៊ើបអង្កេតជាតិ ការចូលរួមរបស់ អោ អាន គឺមិនស្វ័យត មិនសកម្ម មិនបង្កើតថ្មី និង មិនផ្ទាល់ បើប្រៀបធៀបទៅនឹងតួនាទីដោយផ្ទាល់និងយ៉ាងសកម្មរបស់ ឌុច ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម [55] ។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតជាតិសន្និដ្ឋានថា អោ អាន មិនស្ថិតនៅក្រោម យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឡើយ ហើយបានទម្លាក់ការចោទប្រកាន់ប្រឆាំងនឹង អោ អាន[56]។

## V. និដ្ឋភាពទូទៅនៃកិច្ចនីតិវិធីបណ្តឹងឧទ្ធរណ៍ និង បញ្ហាដែលបានលើកឡើង

មានបណ្តឹងឧទ្ធរណ៍ចំនួន ៣ នៅចំពោះមុខអង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២។ សហព្រះរាជអាជ្ញាជាតិ[57] និង អោ អាន[58] បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះ ស្រាយ (ដីកាចោទប្រកាន់) នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ និង ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨។ ចំណែកឯ

---

[52] ដីកាលើកលែងចោទប្រកាន់ (ឯកសារ D359) កថាខណ្ឌ ៥០១, ៥៣៣-៥៣៥។

[53] ដីកាលើកលែងចោទប្រកាន់ (ឯកសារ D359) កថាខណ្ឌ ៥៣៣។

[54] ដីកាលើកលែងចោទប្រកាន់ (ឯកសារ D359) កថាខណ្ឌ ៤៦៧-៤៨៤, ៥៣៦-៥៤២។

[55] ដីកាលើកលែងចោទប្រកាន់ (ឯកសារ D359) កថាខណ្ឌ ៥៤៣-៥៥១, ៥៥៣។

[56] ដីកាលើកលែងចោទប្រកាន់ (ឯកសារ D359) កថាខណ្ឌ៥៥៤-៥៥៥។

[57] សំណុំរឿង ០០៤/២ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ ជូនដំណឹងជាភាសាខ្មែរនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ និងជាភាសាអង់គ្លេសនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩ ឯកសារ D360/8/1 ("បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1)")។

[58] សំណុំរឿង ០០៤/២ បណ្តឹងឧទ្ធរណ៍របស់ អោ អាន លើដីកាដំណោះស្រាយ(ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)របស់សហចៅក្រមស៊ើបអង្កេតជាតិ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨ និងជាភាសាខ្មែរនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩ ឯកសារ D360/5/1 ("បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1)")។

សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ(ដីកាលើកលែងចោទប្រកាន់) នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ [59] ។ ចម្លើយតបត្រូវបានដាក់ដោយ អោ អាន និង សហព្រះរាជអាជ្ញាអន្តរជាតិ នៅថ្ងៃទី២១ [60] ថ្ងៃទី២២ [61] និងថ្ងៃទី២៧ [62] ខែកុម្ភៈ ឆ្នាំ២០១៩ ហើយបានដាក់ការឆ្លើយតប នៅថ្ងៃទី១ [63] និងថ្ងៃទី៣ [64] ខែមេសា ឆ្នាំ២០១៩។ សហព្រះរាជអាជ្ញាជាតិមិនបានដាក់ចម្លើយតប ឬការឆ្លើយតបឡើយ។

ទោះបីជាភាគីនឹងបង្ហាញសារណាររបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍កាន់តែលម្អិតនៅក្នុងអំឡុងពេលសវនាការអសាធារណៈមួយផ្នែកក្តី ក៏អង្គបុរេជំនុំជម្រះយល់ឃើញថា មានគុណប្រយោជន៍សម្រាប់ប្រយោជន៍តម្លាភាព
ក្នុងការផ្តល់សេចក្តីសង្ខេបខ្លីលើបញ្ហាដែលបានលើកឡើងនៅក្នុងកិច្ចដំណើរការនីតិវិធី។

---

[59] សំណុំរឿង ០០៤/២ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨ និងជាភាសាខ្មែរនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ ឯកសារ D359/3/1 (“បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1)”)។

[60] សំណុំរឿង ០០៤/២ ចម្លើយតបរបស់ អោ អាន ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (ឯកសារ D359) ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ ដាក់ និងជូនដំណឹងជាភាសាអង់គ្លេស ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ និងជាភាសាខ្មែរនៅថ្ងៃ ១៩ ខែមីនា ឆ្នាំ២០១៩ ឯកសារ D359/3/4។

[61] សំណុំរឿង ០០៤/២ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩ ជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០១៩ និងជាភាសាខ្មែរនៅថ្ងៃ១៥ ខែមីនា ឆ្នាំ២០១៩ ឯកសារ D360/9។

[62] សំណុំរឿង ០០៤/២ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជជាតិប្រឆាំងនឹងដីកាបញ្ជូនទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ ជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ និងជាភាសាខ្មែរនៅថ្ងៃ១៥ ខែមីនា ឆ្នាំ២០១៩ ឯកសារ D360/10។

[63] សំណុំរឿង ០០៤/២ ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាសម្រេចបញ្ជូនរឿតទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ ជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ និងជាភាសាខ្មែរនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ ឯកសារ D360/11។

[64] សំណុំរឿង ០០៤/២ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយតបរបស់ អោ អាន ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (ឯកសារ D359) ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ ជូនដំណឹងជាភាសាខ្មែរនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ ឯកសារ D359/3/5។

ដោយពេលវេលាមានកម្រិត យើងសូមសង្ខេបជូនតែបណ្តឹងឧទ្ធរណ៍ប៉ុណ្ណោះ ដោយយើងមិនសង្ខេបជូននូវចម្លើយតប ឬការឆ្លើយតបឡើយ។

**ក. បណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ)**

អោ អាន លើកឡើងមូលដ្ឋានបណ្តឹងឧទ្ធរណ៍ចំនួន១៨ ក្នុងការគាំទ្រទឡ្ហីករណ៍របស់ខ្លួនថា អង្គបុរេជំនុំជម្រះត្រូវតែបដិសេធដីកាដំណោះស្រាយ(ដីកាបញ្ជូនទៅជំនុំជម្រះ) និង លើកលែងចោទប្រកាន់។

នៅក្នុងមូលដ្ឋានទី១នៃបណ្តឹងឧទ្ធរណ៍ អោ អាន ផ្តល់ទឡ្ហីករណ៍ថា ការចេញដីកាដំណោះស្រាយចំនួនពីរផ្សេងគ្នា និងផ្ទុយគ្នា មិនធ្លាប់មានពីមុន គឺមានវិសមិតភាពទៅនឹងក្របខ័ណ្ឌច្បាប់ អ.វ.ត.ក និងរំលោភសិទ្ធិរបស់ខ្លួន និង គោលការណ៍សច្ចភាពផ្លូវច្បាប់។ អោ អាន សន្និដ្ឋានថា វិមតិសង្ស័យដែលកើតចេញមកពីការចេញដីកាបញ្ជូនទៅជំនុំជម្រះ រួមជាមួយនឹងដីកាសម្រេចលើកលែងចោទប្រកាន់ដែលមានលក្ខណៈផ្ទុយគ្នា ត្រូវតែដោះស្រាយជាប្រយោជន៍ដល់គាត់។ ហេតុដូច្នេះ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ត្រូវតែបដិសេធចោល[65]។

នៅក្នុងមូលដ្ឋានទី២ ដល់ទី៧ នៃបណ្តឹងឧទ្ធរណ៍របស់ខ្លួន អោ អាន ចោទថា ការកំណត់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថាខ្លួនស្ថិតក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ហើយស្ថិតក្រោមយុត្តាធិការបុគ្គលរបស់តុលាការ គឺផ្អែកលើកំហុសអង្គច្បាប់ និងអង្គហេតុជាច្រើន ដែលនាំឱ្យដីកាដំណោះស្រាយ(ដីកាបញ្ជូនទៅជំនុំជម្រះ)ឥតបានការ[66]។

មូលដ្ឋានទី៨ ដល់ ១៧ នៃបណ្តឹងឧទ្ធរណ៍របស់ អោ អាន ពាក់ព័ន្ធការចោទថាមានកំហុសលើច្បាប់សារធាតុ ទាក់ទិននឹងការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតទៅលើយុត្តាធិការបុគ្គល និងយុត្តាធិការលើរឿងក្តី[67]។

---

[65] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ២, ២០-៣៦។

[66] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៣, ៣៧-១៦៤។

[67] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៤, ១៦៥-២០៦។

នៅក្នុងមូលដ្ឋានទី១៨ និងមូលដ្ឋានចុងក្រោយនៃបណ្ដឹងឧទ្ធរណ៍របស់ខ្លួន អោ អាន តវ៉ាថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុស ឬ រំលោភលើឆន្ទានុសិទ្ធិរបស់ខ្លួនដែលខកខានមិនបានបដិសេធ ឬ ផ្អាកកិច្ចនីតិវិធីក្នុងសំណុំរឿង០០៤/០២ ដើម្បីធានាភាពត្រឹមត្រូវ និងសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី និងសិទ្ធិរបស់គាត់[68]។

## ខ. បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ)

នៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ខ្លួន សហព្រះរាជអាជ្ញាជាតិស្នើឲ្យអង្គបុរេជំនុំជម្រះបដិសេធសំណុំរឿងប្រឆាំងនឹង អោ អាន ផ្អែកលើទស្សនៈរបស់ខ្លួនថា អោ អាន គ្មានពិរុទ្ធភាព និង មិនស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឡើយ[69]។

ចំពោះចំណុចទី១ របស់គាត់ សហព្រះរាជអាជ្ញាជាតិ ពិចារណាឃើញថា ភស្តុតាងបង្ហាញថា អោ អាន គ្មានសិទ្ធិអំណាចស្វយ័ត ឬសិទ្ធិអំណាចជាក់ស្ដែងឡើយ ទោះបីជា អោ អាន មានតួនាទីនៅក្នុងឋានានុក្រមនៃ ប.ក.ក ក្ដី[70] ហើយ អោ អាន បានត្រឹមតែអនុវត្តតាមបញ្ជាថ្នាក់លើតែប៉ុណ្ណោះ ជាពិសេស កែ ពក[71]។

ទាក់ទិននឹងចំណុចទី២ របស់គាត់ សហព្រះរាជអាជ្ញាជាតិ ផ្ដល់ទឡ្ហីករណ៍ថា រាជរដ្ឋាភិបាលកម្ពុជា ដែលជាស្ថាបនិកមួយនៃ អ.វ.ត.ក អាចកម្រិតយុត្តាធិការបុគ្គលរបស់តុលាការ ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និង អង្គបុរេជំនុំជម្រះ គួរតែអនុវត្តស្របតាមទស្សនៈរបស់រាជរដ្ឋាភិបាលដែលថា ពាក្យ "មេដឹកនាំជាន់ខ្ពស់" ក្ដោបតែទៅលើបុគ្គលមួយចំនួនតូចដែលជា "សមាជិកមជ្ឈិមបក្ស និងគណៈអចិន្ត្រៃយ៍" ប៉ុណ្ណោះ

---

[68] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៥, ២០៧-២៣០។

[69] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៦៨-៩៨។

[70] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៧២, ៧៥, ៨២-៨៣។ ជាទូទៅ សូមមើល កថាខណ្ឌ ៦៨-៨៣។

[71] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ០៧-៧២, ៧៥, ៨២-៨៣។

ចំណែកឯពាក្យ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" សំដៅតែចំពោះប្រធាន មន្ទីរសន្តិសុខ ស២១ ឈ្មោះ កាំង ហ្កេចអ៊ាវ ហៅ ឌុច តែប៉ុណ្ណោះ[72]។

### គ. បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់)

នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងមូលដ្ឋានចំនួន៦ ដោយទាញទឡ្ហីករណ៍ថា សហចៅក្រមស៊ើបអង្កេតជាតិមានកំហុសអង្គច្បាប់ និង អង្គហេតុ ដែលរកឃើញថា អោ អាន មិនស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[73]។ ទី១ គាត់តវ៉ាថា សហចៅក្រមស៊ើបអង្កេតជាតិ បានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយខកខានមិនបានធ្វើសេចក្តីសន្និដ្ឋានតាមផ្លូវច្បាប់ ថាតើអង្គហេតុដែលគាត់បានរកឃើញតាមរយៈភស្តុតាងដែលបានបង្ហាញនោះ ចាត់ទុកជាបទឧក្រិដ្ឋនានាដែលស្ថិតនៅក្នុងយុត្តាធិការ អ.វ.ត.ក ឬបង្ហាញអំពីពិរុទ្ធភាពរបស់ អោ អាន ដែរឬទេ[74]។ សហព្រះរាជអាជ្ញាអន្តរជាតិថែមទាំងសម្តែងការមិនពេញចិត្តថា ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់)ផ្តល់ទម្ងន់លើសលប់ទៅលើការបង្ខិតបង្ខំ ការគំរាម និង បញ្ជាពីថ្នាក់លើ ក្នុងការកំណត់ថា អោ អាន មិនស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ[75]។

សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់ទៀតថា ការអះអាងរបស់សហចៅក្រមស៊ើបអង្កេតជាតិដែលថា ឌុច គឺ "ជនដែលទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់"នោះ គឺមិនត្រឹមត្រូវតាមច្បាប់ឡើយ[76]។ ជាងនេះទៀត សហព្រះរាជអាជ្ញាអន្តរជាតិចោទថា សហចៅក្រមស៊ើបអង្កេតជាតិវាយតម្លៃ ដោយមិនត្រឹមត្រូវទៅលើភាពគួរឱ្យជឿជាក់បាននៃភស្តុតាង[77] និង មានកំហុសជាច្រើនក្នុងការកំណត់អង្គហេតុ ពាក់ព័ន្ធនឹង កម្រិតនៃការទទួលខុសត្រូវ

---

[72] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៨៤-៩៣។

[73] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ១៣។ ជាទូទៅ សូមមើល កថាខណ្ឌ ១៤-៩៩។

[74] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ១៤-៣១។

[75] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៣២-៤៦។

[76] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៤៧-៥៧

[77] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៥៨-៦៤។

និងការចូលរួមប្រព្រឹត្តបទល្មើស របស់ អោ អាន[78]។ នៅក្នុងមូលដ្ឋានចុង ក្រោយនៃបណ្ដឹងឧទ្ធរណ៍របស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សហចៅក្រមស៊ើបអង្កេតជាតិ មានកំហុស ដោយខកខានមិនបានពិចារណាទៅលើឥទ្ធិពលនៃតួនាទីសំខាន់របស់ អោ អាន នៅក្នុងអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម ចំពោះបញ្ហាថាតើ អោ អាន គឺជាជនម្នាក់ក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" សម្រាប់គោលបំណងនៃយុត្តាធិការបុគ្គលដែរឬទេ[79]។

ជាចុងក្រោយ ដែលមិនមែនជាមូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាអន្តរជាតិស្នើថា ក្នុងករណីដែលអង្គបុរេជំនុំជម្រះមិនអាចសម្រេចក្នុងសំឡេងភាគច្រើនលើសលប់លើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយដែលផ្ទុយគ្នានោះ វិធានផ្ទៃក្នុង ករណីយុត្តិសាស្ត្រ និងក្របខ័ណ្ឌច្បាប់នៃ អ.វ.ត.ក កំណត់ឱ្យសំណុំរឿងនេះបន្តដល់ការជំនុំជម្រះដោយផ្អែកលើមូលដ្ឋាននៃដីកាដំណោះស្រាយ(ដីកាសម្រេចចោទប្រកាន់)[80]។

ហេតុដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើឱ្យអង្គបុរេជំនុំជម្រះ បដិសេធដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) ហើយសន្និដ្ឋានថា អោ អាន គឺជាជនម្នាក់ក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ និង បញ្ជូន អោ អាន ទៅជំនុំជម្រះដោយផ្អែកលើដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ)[81]។

## VI. សេចក្តីសន្និដ្ឋាន

អង្គបុរេជំនុំជម្រះបានផ្តល់របាយការណ៍សង្ខេបលើសំណុំរឿងនេះ និងកិច្ចដំណើរការនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ ដើម្បីជាប្រយោជន៍យុត្តិធម៌ និងតម្លាភាព ប៉ុន្តែនៅតែទទួលស្គាល់គោលការណ៍រក្សាភាពសម្ងាត់នៅក្នុងដំណាក់កាលបុរេជំនុំជម្រះ។ របាយការណ៍នេះនឹងដាក់ចូលទៅក្នុងសំណុំរឿង ហើយសាធារណជននឹងអាចរកមើលបាននៅលើគេហទំព័ររបស់ អ.វ.ត.ក។

---

[78] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៦៥-៨៤។

[79] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៨៥-៨៩។

[80] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ១០០-១០៧។

[81] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ១២។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩

**អង្គបុរេជំនុំជម្រះ**

**ប្រធាន**

**ប្រាក់ គីមសាន** **Olivier BEAUVALLET** **ន័យ ថុល** **Kang Jin BAIK** **ហួត វុទ្ធី**